| | |
|---|---|
| **ទុត្ថា**<br>**"នេះគឺជារឿងរ៉ាវរបស់ក្មេងស្រីម្នាក់ដែលលែង និយាយអ្វីទាំងអស់ "**<br>នាងមានឈ្មោះថា **ជា ឌ**<br>នាងមានសម្រស់ស្រស់ស្អាតមែនទែន គឺស្អាតដូចជាទេពអប្សរ **ឌ**<br><br>**ទុត្ថា សុវណ្ណា ធារី សុខលី**<br>**ចំរៀង " បទ ទេពកញ្ញា "**<br><br>- កេសារំសាយ អណ្តែតសាយភាយ<br>ចាំងពណ៌សុវណ្ណ សម្ផស្សពណ៌ភ្លុក<br>ចក្ខុភាំងភាន់ រេរាំពើនពន្ធ័<br>របាំអំពៅ ។<br>- វាយោរំភើយ ធម្មជាតិផ្តល់ហើយ<br>បែតងវាលស្មៅ ឥតបីហ្មងសៅ<br>ទ្រូបាទទេពកញ្ញា គយគន់យូរទៅ<br>ជាប់នៅនេត្រា ។<br>- ព្រះជាសាក្សី គជំកេរនាគបី<br>របាំសួគ៌ា ស្តែងថ្ងៃព្រហស្បតិ៍<br>អោយខ្ញុំទស្សនា ទុកជាទ្រព្យា<br>អង្គអញតទៅ ។ | |

| | |
|---|---|
| **ទុត្ថា**<br>**ឥឡូវសូមអញ្ជើញស្តាប់រឿងរបស់ ជា ។**<br><br>**សុវណ្ណ**<br>នេះគឺជាឆ្នាំ ១៩៧៦<br>**ជា**គឺជាក្មេងស្រីវ័យជំទង់ម្នាក់<br>នាងមានអាយុ ១៣ឆ្នាំហើយ។<br><br>**ជា**មានរូបរាងស្រស់ស្អាតណាស់។<br>រូបរាងទន់ភ្លន់របស់នាងបង្ហាញពីការចាប់ផ្តើមក្លាយខ្លួនជានារីក្រមុំម្នាក់ ។ នាងមានសក់រួញអង្កាញដីស្បែករលោង បបូរមាត់ពេញ ភ្នែកមូលធំពណ៌ត្នោត និងរោមភ្នែកវែងៗ ។<br><br>**ទុត្ថា**<br>នៅពេលដែលនាងធ្វើដំណើរ ពួកយោធាតាមសម្លឹងមើលនាងជានិច្ច ។<br><br>**សុវណ្ណា**<br>ឪពុកម្តាយរបស់**ជា** ខំការពារនាងខ្លាំងណាស់ ។ ពួកគាត់បានយកភក់មកបាតលើមុខនាងដើម្បីបិតបាំងសម្រស់របស់នាង ។ នាងតែងតែយកក្រមាទទូរក្បាលជានិច្ច ។ | |

| | |
|---|---|
| **ទុត្ថា**<br>នៅពេលដែលនាងធ្វើដំណើរ ពួកទាហានអាពតតាមសម្លឹងមើលនាងជានិច្ច ។<br><br>**សុវណ្ណា**<br>នាយប់មួយក្នុងខែមិនា ឆ្នាំ១៩៧៦ យោធាបីនាក់បានមកខ្ទមដែលគ្រួសារជីវា  រស់នៅ ។<br><br>**ទុត្ថា**<br>**" ណែ៎..មិត្ត ! អង្គការត្រូវការស្នើកូនរបស់មិត្តឯងនឹង... ទៅកាច់ពោត ។ "**<br><br>**សុវណ្ណា**<br>ម្តាយជីវាស្ទុះទៅឱបកូន។<br>គាត់យំហើយនិយាយថា "**មិត្តបងអើយ...យកខ្ញុំជំនួសវិញទៅ....ខ្ញុំធ្វើការ លឿនជាង ហើយាច់ពោតជូនអង្គការបានច្រើនជាងកូនខ្ញុំទៀត....**"<br>ឪពុកជីវាលត់ជង្គង់អង្វរៈ "**មិត្តបងយកខ្ញុំទៅវិញទៅ ខ្ញុំមានកម្លាំងខ្លាំងជាង.....ខ្ញុំអាចធ្វើការជូនមិត្តបងមួយយប់ទល់ភ្លឺក៏បានដែរ.....**"<br><br>**ទុត្ថា**<br>" មិនបានទេ......អង្គការត្រូវការតែជីវា ប៉ុណ្ណោះ។"<br>គ្មានអ្វីអាចតវ៉ាបានឡើយ។ តវ៉ាជាមួយអង្គការ គឺគ្មានប្រយោជន៍នោះទេ ។ | |

អង្គការប្រាប់អោយធ្វើអ្វី គឺយើងត្រូវតែធ្វើ ។

**សុវណ្ណា**

ពួកយោធាចាប់យក**ដា** ទៅក្នុងព្រៃ។

**ដា**ងាកក្រោយសម្លឹងមើលឪពុកម្តាយរបស់ខ្លួនរហូត

ផុតកន្ទុយភ្នែក ។

នៅក្នុងរាត្រីងងឹតម្តាយរបស់ជាយំសោកដូចអកព្រាត់

កូន ។

ពិតដូចសម្តីពួកទាហានបានសន្យាមែនពួកគេបញ្ជូន**ដា**

មកអោយឪពុកម្តាយនាងវិញនៅព្រឹកស្អែក ។

ប៉ុន្តែនាងលែងជា **ដា**ដែលស្រស់ស្អាតនិងញញឹមរស់

រាយរាក់ទាក់ដូចកាលពីមុនទៀតហើយ។មុខនាងឡើង

ហើម ស្នាធ្លាក់ចុះ ដៃសំយុងហាក់គ្មានជីវិត។ ចាប់

តាំងពីពេលនោះមក**ដា**ឈប់និយាយស្តីជារៀងរហូត។

**នាង**បោះជំហានដើរដូចមនុស្សគ្មានវិញ្ញាណ។

**នាង**តែងតែឱនមុខចុះជានិច្ច ។

គ្មាននរណាមកជិត**ដា**ឡើយ ។

គ្មាននរណានិយាយរក**ដា**ឡើយ ។

មនុស្សម្នានាំគ្នាគេចមុខចេញ

នៅពេលដែល**នាង**ដើរកាត់។

<table>
<tr>
<td>
ឆរី<br>
កាលណោះ..ខ្ញុំក៏នៅទីនោះដែរ គឺនៅក្នុងជំរំជាមួយ<br>
នឹងនាងខ  កាលពីឆ្នាំ ១៩៧៦ ខ្ញុំក៏តែងតែងាកមុខ<br>
ចេញពី ដារដែរ នៅពេលដែលនាងដើរកាត់ម្តងៗ។<br>
ខ្ញុំធ្វើដូចអ្នកដ៏ទៃដែរ គឺពួកយើងធ្វើហាក់ដូចជា<br>
ដារគ្មានរូបរាង។<br>
<br>
ឥឡូវនេះ៣០ឆ្នាំក្រោយមក ដាររស់នៅក្នុងភូមិរបស់ខ្ញុំ។<br>
គាត់គឺជាស្ត្រីស្ងៀមស្ងាត់ម្នាក់ ។<br>
គ្មាននរណាមកជិតដារឡើយ ។<br>
គ្មាននរណានិយាយរកដារឡើយ ។<br>
មនុស្សម្នាងាកមុខចេញ ពេលដែលដារដើរកាត់ ។<br>
រាល់ពេលអោយតែខ្ញុំឃើញគាត់ បេះដូងខ្ញុំតែងតែ<br>
លោតញាប់ខុសធម្មតា ។<br>
ខ្ញុំមានអារម្មណ៍ខុសឆ្គង គឺខុសឆ្គងធ្ងន់មែនទែន ។<br>
ខ្ញុំនិយាយទៅកាន់ខ្លួនឯង : ˝កាលណោះខ្ញុំគ្រាន់តែជា<br>
ក្មេងស្រីតូចម្នាក់ ។ ខ្ញុំមិនអាចជួយអ្វីបាននោះទេ ។<br>
ខ្ញុំធ្វើតាមតែចាស់ៗប្រាប់....ខ្ញុំគ្រាន់តែជាក្មេងស្រីតូច<br>
ម្នាក់ប៉ុណ្ណោះ ....។˝<br>
ខ្ញុំនិយាយទៅកាន់ខ្លួនឯងថា : ˝ ខ្ញុំក្បត់ដារ....ខ្ញុំបានទុក<br>
អោយនាងនៅភិតភ័យតែឯង...ខ្ញុំជាមនុស្សកំសាក។ ˝
</td>
<td>
- ព្រះជាសាក្សី          គជំកេរនាគបី<br>
រចាំសូត្រ          ស្តែងថ្ងៃព្រហស្បតិ៍<br>
អោយខ្ញុំទស្សនា          ទុកជាទ្រព្យា<br>
អង្គអញតទៅ ។
</td>
</tr>
</table>

| | |
|---|---|
| ថ្ងៃនេះ ខ្ញុំឃើញ**ដារា** ។បេះដូងខ្ញុំលោតញាប់ខ្លាំងណាស់ ។ ខ្ញុំចាប់ផ្ដើមបែកញើស ។ ខ្ញុំត្រូវតាំងចិត្ត ។ ខ្ញុំមិនអាចទ្រាំទ្រនឹងអារម្មណ៍ខុសឆ្គងបែបនេះទៀតទេ<br><br>ខ្ញុំក៏បោះជំហានយឺតៗ សំដៅទៅរក**ដារា**....មួយជំហានហើយមួយជំហានទៀត.....:<br>"**ដារា**....អត់ទោសអោយខ្ញុំផងបានទេ....សូមយល់ចិត្តខ្ញុំហើយអត់ទោសអោយខ្ញុំផងទៅ....សូមមកជាមួយខ្ញុំ យើងអង្គុយហូបតែហើយជជែកគ្នាលេងបន្តិចបានទេ?"<br><br>**ដារា**មិនបានក្រឡេកមើលមុខខ្ញុំទេ ហើយក៏គ្មាននិយាយអ្វីដែរ។ ខ្ញុំប្រហែលជានិយាយយឺតពេលបន្តិចហើយ ។<br><br>ប៉ុន្តែថ្ងៃស្អែក ខ្ញុំនឹងព្យាយាមម្ដងទៀត ។ | **បទទេពកញ្ញាបន្ទីពីចំងាយ**<br><br>**- ព្រះជាសាក្សី គជំកេរនាគបី**<br>**របាំសូត្រ ស្តែងថ្ងៃព្រហស្បតិ៍**<br>**អោយខ្ញុំទស្សនា ទុកជាទ្រព្យា**<br>**អង្គអញតទៅ ។** |